# សុន្ទរកថា
# ឯកឧត្តម អ៊ិត សំហេង
# រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
# ក្នុងឱកាសខួបលើកទី ១០ របស់មជ្ឈមណ្ឌលជាតិនៃជនពិការ
# ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៦

-សូមគោរព សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់

-ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល

-ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ភ្ញៀវជាតិ អន្តរជាតិ មន្ត្រីរាជការ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស បងប្អូនជនរួមជាតិ ព្រមទាំងបងប្អូនជនពិការទាំងអស់ ដែលមានវត្តមាននៅទីនេះជាទីមេត្រី !

ជាបឋម តាងនាមមន្ត្រីរាជការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក សមាជិកា មជ្ឈមណ្ឌលជាតិនៃជនពិការ និងបងប្អូនជនពិការទាំងអស់ ដែលមានវត្តមាននៅទីនេះ និងនៅទូទាំងប្រទេស សូមសំដែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង**លោកជំទាវ** ដែលបានឆ្លៀតឱកាសដ៏មមាញឹក អញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងឱកាស ខួបលើកទី **១០ឆ្នាំ** នៃការបង្កើតមជ្ឈមណ្ឌលជាតិនៃជនពិការ ។ វត្តមានដ៏ឧត្តុងឧត្តមរបស់សម្តេច **ហ៊ុន សែន** និង**លោកជំទាវ** បានបង្ហាញច្បាស់ពីការយកចិត្តទុកដាក់ ការលើកទឹកចិត្ត ការសន្តោសប្រណីរបស់ **សម្តេច** និង**លោកជំទាវ** ចំពោះបងប្អូនជនពិការ ហើយលើការជាក់ស្តែងកន្លងមក **សម្តេច** និង**លោកជំទាវ** តែងផ្តល់នូវ ការគាំទ្រ លើកទឹកចិត្ត ជំនួយឧបត្ថម្ភជាច្រើន ជាបន្តបន្ទាប់ដល់ជនពិការ ។ ថ្ងៃស្អែកនេះ គឺជាថ្ងៃទី **៤ មេសា** គឺថ្ងៃខួបកំណើតដ៏ឧត្តុងឧត្តមរបស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា គម្រប់ **៥៥**ឆ្នាំ ឈានចូល **៥៦**ឆ្នាំ ខ្ញុំបាទសូមយកឱកាសនេះ តាងនាមមន្ត្រី រាជការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បងប្អូនជនពិការទូទាំងប្រទេស និងអង្គពិធីទាំងមូល សូមគោរពជូនពរដ៏មហាប្រសើរចំពោះ សម្តេច សូមសម្តេចមានសុខភាពល្អបរិបូណ៌ ថាមពលខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីដឹកនាំប្រទេសជាតិឆ្ពោះទៅកាន់វឌ្ឍនភាពឆាប់រហ័ស ។ សូម **សម្តេច** និង**លោកជំទាវ** បុត្រា បុត្រី ព្រមទាំងចៅ សូមប្រកបដោយពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

មជ្ឈមណ្ឌលជាតិនៃជនពិការ ត្រូវបានកកើតឡើងតាមឆន្ទៈ នៃសេចក្តីប្រកាសទសវត្សជនពិការ ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក UNESCAP ១៩៩៣ ដល់ ២០០៣ ដែលឥឡូវនេះបានបន្តពីឆ្នាំ ២០០៣ ដល់ ២០១២ មានឈ្មោះថា BIWAKO Millennium Framework for Action ។ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសេនាធិការបានចូលរួមយ៉ាងសកម្មក្នុងនាមជាសមាជិក UN-SCAP ដើម្បីជំរុញ និងអនុវត្តនូវសេចក្តីប្រកាសទសវត្សថ្មី ប្រកបដោយជោគជ័យ ។

ក្នុងស្មារតីខាងលើនេះ មជ្ឈមណ្ឌលជាតិនៃជនពិការ ត្រូវបានបង្កើតឡើង និងសម្ពោធបើកដំណើរការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នាថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ១៩៩៧ ដែលក្នុងឱកាសនោះ

សម្តេច បានផ្តល់អនុសាសន៍ដ៏មានតម្លៃថា " យើងទាំងអស់គ្នាខិតខំធ្វើឱ្យ មជ្ឈមណ្ឌលជាតិដើម្បីជនពិការ ក្លាយជាចំណុចកណ្តាលនៃមហាវិថីជីវិតថ្មីរបស់ជនពិការ នៅគ្រប់ទីកន្លែង ។ ជនពិការ គឺជនដែលលែងពិការទៀតហើយ "។

**១០**ឆ្នាំកន្លងមកនេះ មជ្ឈមណ្ឌលជាតិនៃជនពិការ បានអនុវត្តតាមអនុសាសន៍របស់សម្តេច ខិតខំប្រែក្លាយជាមជ្ឈមណ្ឌលកណ្តាល ជាអ្នកផ្តល់សេវាកម្មផ្ទាល់ ជាអ្នកជំនាញការ និងជាប្រភពធនធានមនុស្សដ៏សំខាន់ ខាងវិស័យពិការភាពរបស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នាពេលបច្ចុប្បន្ន។

ជាក់ស្តែងមជ្ឈមណ្ឌលជាតិនៃជនពិការ មានកម្មវិធី ចំនួន៥ ត្រូវបានបង្កើតឡើងដែលមានជាអាទិ៍ :

-កម្មវិធីសិប្បកម្មផលិតដោយជនពិការ ដើម្បីរកប្រាក់ចំណូលសម្រាប់បងប្អូន ដែលប្រកបមុខរបរផ្នែកសិប្បកម្មលក់ក្នុងស្រុក និងនាំចេញទៅក្រៅប្រទេស។

-កម្មវិធីស្តារលទ្ធភាពលកម្មតាមសហគមន៍ ដែលបម្រើសេវាកម្មជូនជនពិការ លើការពង្រឹងកាយសម្បទាថែទាំសុខភាព និងផ្សព្វផ្សាយប្រធានបទពិការភាព ពិសេសកុមារពិការ ដើម្បីបានចូលសាលារៀន នៅពេលក្មួយៗដល់អាយុចូលសាលា។

-គម្រោងសេវាព័ត៌មាន និងទំនាក់ទំនង ដែលកំពុងសហការជាមួយស្ថាប័នជាតិ អន្តរជាតិ និងវិស័យឯកជនដើម្បីបញ្ជូនបងប្អូនពិការ ទៅតាមគ្រឹះស្ថានសិក្សា ចំណេះទូទៅ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងរកការងារធ្វើ។

-គម្រោងបណ្តុះបណ្តាល និងព័ត៌មាន ដើម្បីអភិវឌ្ឍន៍មុខរបរ ជួយដល់បងប្អូនពិការ ជៀសវាងចំណាកស្រុកនិងធ្វើការបណ្តុះបណ្តាលមុខរបរជំនួញគ្រប់ប្រភេទ ដើម្បីបងប្អូនអាចប្រកបរបរនៅនឹងសហគមន៍ផ្ទាល់តែម្តង។

-កម្មវិធីវេទិកាជនពិការ ដែលទទួលបន្ទុកផ្សព្វផ្សាយវិស័យពិការភាពទូទាំងប្រទេស និងចលនាតាមប្រព័ន្ធផ្សព្វផ្សាយទៅគ្រប់ទិសទីលើ **១២៦**ប្រទេស ដើម្បីធ្វើការអប់រំដល់សង្គមឱ្យបានយល់ដឹង ក្នុងការកាត់បន្ថយកំណើនជនពិការ ដោយទប់ស្កាត់តាមកម្មវិធីបង្ការផ្សេងៗ ជូនដំណឹងពីសេវាកម្ម ពិសេសស្នាដៃ និងលទ្ធផល ដែលអង្គការជាតិ និងអន្តរជាតិ និងជនពិការធ្វើបាន។

សរុបមក ជនពិការដែលទទួលបានសេវា និងផលផ្ទាល់ពីមជ្ឈមណ្ឌលជាតិនៃជនពិការ មានប្រមាណ **១៨.០០០**នាក់ និងអ្នកទទួលផលដោយប្រយោល តាមកម្មវិធីមានប្រមាណជាង **២១៦.០០០**នាក់ និងតាមរយៈយុទ្ធនាការផ្សព្វផ្សាយវេទិកាជនពិការ ប្រជាពលរដ្ឋស្ទើរទូទាំងប្រទេស បានទទួលការយល់ដឹងពីបញ្ហាពិការភាព និងលប់បំបាត់ចោលការរើសអើងមកលើជនពិការជាបណ្តើរៗ និងបានទទួលព័ត៌មានយ៉ាងច្រើន ក្នុងការទប់ស្កាត់កំណើននៃជនពិការនៅកម្ពុជាយើង។ ខ្ញុំសូមយកឱកាសនេះ កោតសរសើរក្រុមប្រឹក្សាភិបាលមជ្ឈមណ្ឌលជាតិនៃជនពិការដែលមាន ឯកឧត្តម **អ៊ឹង ទាស៊ាម** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធាន និងមានលោក **យី វាសនា** ជានាយកប្រតិបត្តិ។ ជាពិសេស ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះ លោក **យី វាសនា** ជាជនពិការដោយជំងឺប៉ូលីយ៉ូ តែបានខិតខំតស៊ូក្នុងជីវិត និងការងារ ការរៀនសូត្រ បង្កើនសមត្ថភាពក្លាយជាអ្នកដឹកនាំចលនាជនពិការកម្ពុជាដ៏ល្អ និងជាសកម្មជន ដែលបានចូលរួមក្នុងវេទិកាជនពិការអន្តរជាតិជាច្រើន ធ្លាប់បានទទួលការសរសើរពីស្ថាប័នពិការភាព នៃប្រទេសជប៉ុនផង។ ក្រៅពីនេះ មានជនពិការជាច្រើន ដែលជាអ្នកដឹកនាំរបស់មជ្ឈមណ្ឌលជាតិនៃជនពិការ មានស្នាដៃល្អរួមចំណែកក្នុងកិច្ចប្រឹងប្រែង រយៈពេល ១០ឆ្នាំ កន្លងមក។ ប្រការនេះ

ជាសក្ខីភាពបង្ហាញថា ជនពិការក៏មានសមត្ថភាពអាចធ្វើអ្វីៗបាន ដូចជនមិនពិការដែរ ហេតុនេះគេត្រូវមើលឃើញសមត្ថភាព ជាជាងពិការភាព។

ខ្ញុំសូមយកឱកាសនេះ អរគុណចំពោះម្ចាស់ជំនួយ របស់មជ្ឈមណ្ឌលជាតិនៃជនពិការ មាន :

- Interchurch Organization for development co-operation (ICCO)
- World Rehabilitation Fund (WRF)
- Adopt-A-Minefield(AAM)
- Baptish World Aid Australia (BWAA)
- UNICEF
- Kangaroo Fund
- Choo Young Moo Fund
- MPDF/World Bank/IFC

ដោយឡែកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានផ្តល់អគារទីស្នាក់ការ សម្រាប់មជ្ឈមណ្ឌលជាតិ នៃជនពិការ ប្រើប្រាស់រយៈពេល ៣០ឆ្នាំ។

ក្នុងឱកាស ខួបលើកទី ១០ របស់មជ្ឈមណ្ឌលជាតិនៃជនពិការ ខ្ញុំសូមឆ្លៀតឱកាសនេះ ជម្រាបជូនថា ដោយអនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក៏ដូចជាអនុសាសន៍ជាបន្តបន្ទាប់របស់ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានកំណត់វិស័យស្តារលទ្ធភាពពលកម្ម និងការផ្តល់សេវាសាធារណៈសម្រាប់ជនពិការ ជាអាទិភាពទី១ ក្នុងចំណោមអាទិភាពទាំង ៦ របស់ក្រសួង។

សមិទ្ធផលនៃវិស័យស្តារលទ្ធភាពពលកម្ម និងការផ្តល់សេវាសម្រាប់ជនពិការ រួមមាន :

-ការផ្សព្វផ្សាយអំពីសិទ្ធិជនពិការ បានអនុវត្តជាជំហានៗ សេវាសម្រាប់ជនពិការ ត្រូវបានរៀបចំបង្កើតជាបន្តបន្ទាប់ និងការរើសអើងចំពោះជនពិការ ត្រូវបានកាត់បន្ថយជាបណ្តើរៗពីសង្គមជាតិយើង។

-សេចក្តីព្រាងច្បាប់ ស្តីពីសិទ្ធិជនពិការ ត្រូវបានពិភាក្សានៅអន្តរក្រសួង និងត្រៀមដាក់ឆ្លងគណៈរដ្ឋមន្ត្រី។

-ក្រសួងបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ១០កន្លែង និងមណ្ឌលស្តារលទ្ធភាពពលកម្ម **១២**កន្លែង ក្នុងនោះមានមណ្ឌលផលិតអវយវៈសិប្បនិម្មិត គ្រឿងផ្សំអវយវៈសិប្បនិម្មិត ១កន្លែង។ ការបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ ចំនួន **១២៥.៣០៥**នាក់ ក្នុងនោះមានបណ្តុះបណ្តាលនៅតាមសាលា និងនៅតាមសហគមន៍តែម្តង។ ក្នុងចំនួនដែលបានបណ្តុះបណ្តាលខាងលើ មានចំនួន**៧៣.៨០៣**នាក់ បានបង្កើតមុខរបរផ្ទាល់ខ្លួន និង **៥៨៨**នាក់ ធ្វើការនៅតាមក្រុមហ៊ុននានា។

-ជនពិការជាអតីតយុទ្ធជន ជាង ៣១.០០០នាក់ កំពុងទទួលរបបឧបត្ថម្ភពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

-ក្រសួងបានផ្តល់អវយវៈសិប្បនិម្មិត **៧៦.៥៦៩**ជើង ព្យាបាលដោយចលនាបានចំនួន **៦០.៨៤៦**នាក់ ផ្តល់រទេះរុញ **១៣.៨៦៣**គ្រឿង និងឈើច្រត់ **៣៦.៧៨៧**គូ។ ដោយអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

ជនពិការដែលទទួលសេវាស្តារលទ្ធភាពពលកម្មតាមមណ្ឌលរដ្ឋ និងអង្គការ NGOs បច្ចុប្បន្ននេះ ឥតបង់ថ្លៃទេ ហើយក្រសួងបានឧបត្ថម្ភប្រាក់ហូប សម្រាប់ជនពិការដែលមកទទួលសេវាតាមមណ្ឌល ១ថ្ងៃ ១.០០០រៀល ក្នុង ១នាក់ ទៀតផង ។

-ក្រសួងបានរៀបចំទិវាជនពិការអន្តរជាតិ **៣ធ្នូ** រៀងរាល់ឆ្នាំ ដើម្បីផ្សព្វផ្សាយសិទ្ធិជនពិការ សមិទ្ធិផលនៃការងារជនពិការ និងលើកទឹកចិត្តដល់ជនពិការ ។

-ក្រសួងបានសហការជាមួយក្រសួងពាក់ព័ន្ធ និងអង្គការនានា បង្កើតអក្សរស្ទាប ភាសា សញ្ញាជាតម្រូវការប្រភេទជនពិការ ។ ទូរទស្សន៍ជាតិកម្ពុជា មានកម្មវិធីព័ត៌មានជាភាសាសញ្ញា សម្រាប់បងប្អូនពិការជាលើកដំបូង ។

-ដោយឡែកចលនាកីឡាជនពិការ មានការរីកចម្រើនគួរជាទីមោទនៈ គណៈកម្មការជាតិប៉ារ៉ាឡាំពិក ដែលមាន សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ជាប្រធាន បានបង្កើតឡើងចាប់តាំងពីឆ្នាំ ១៩៩៧ ដោយមានការឧបត្ថម្ភគាំទ្រពី សម្តេចនាយករដ្ឋមន្ត្រីផ្ទាល់ និងការគៀងគរជំនួយឧបត្ថម្ភពីសប្បុរសជននៅក្នុងប្រទេស ក៏ដូចជាអ្នកផ្តល់ជំនួយមួយចំនួន បានបង្កលក្ខណៈឧបត្ថម្ភដល់ក្រុមកីឡាជនពិការយើងហ្វឹកហាត់ និងចេញទៅប្រកួតជាអន្តរជាតិជាបន្តបន្ទាប់ សរុបឈ្នះបានមេដាយមាស ចំនួន **១៣**, មេដាយប្រាក់ចំនួន **២៣** និងមេដាយសំរិទ្ធ ចំនួន **១២** ទាំងនេះបង្ហាញពីការរួមចំណែកលើកកម្ពស់កិត្តិយសព្រះរាជាណាចក្រកម្ពុជា លើឆាកអន្តរជាតិទៀតផង ។

**-សម្តេចនាយករដ្ឋមន្ត្រី និងលោកជំទាវ ជាទីគោរព !**

**-អង្គពិធីទាំងមូលជាទីមេត្រី !**

ការប្រារព្ធខួបលើកទី១០ របស់មជ្ឈមណ្ឌលជាតិនៃជនពិការថ្ងៃនេះ ជាការលើកទឹកចិត្តខ្លាំងណាស់ ចំពោះចលនាដើម្បីសិទ្ធិ និងការអភិវឌ្ឍន៍ជនពិការកម្ពុជាយើង ខ្ញុំបាទសូមតាងនាមមន្ត្រីរាជការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងបុគ្គលិកទាំងអស់នៃមជ្ឈមណ្ឌលជាតិជនពិការ ប្តេជ្ញាថា ខិតខំពង្រឹងពង្រីកសមិទ្ធផលទាំងឡាយ និងបង្កើតបានស្នាដៃថ្មីៗទៀត រួមចំណែកអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ។

ជាចុងបញ្ចប់ ខ្ញុំសូមយកឱកាសនេះ សំដែងនូវការកោតសរសើរស្មារតីសហការ ជួយឧបត្ថម្ភគាំទ្រទាំងស្មារតី និងសំភារៈ ដល់មជ្ឈមណ្ឌលជាតិនៃជនពិការ ដើម្បីជាប្រយោជន៍នៃជនពិការនៅកម្ពុជា ពីសំណាក់អ្នកផ្តល់ជំនួយ អង្គការជាតិ អន្តរជាតិនានា ក្រុមហ៊ុន និងសប្បុរសជន។ ខ្ញុំសូមយកឱកាសនេះ អំពាវនាវដល់សហគមន៍អ្នកផ្តល់ជំនួយ និងសប្បុរសជនទាំងអស់ សូមបន្តជួយឧបត្ថម្ភគាំទ្របន្ថែម ដើម្បីលើកស្ទួយសុខុមាលភាពបងប្អូនជនពិការ ។ ព្រមជាមួយនេះផងដែរ ខ្ញុំក៏សូមអំពាវនាវដល់បងប្អូនពិការ ត្រូវខិតខំតស៊ូជំនះគ្រប់ការលំបាក និងឈានទៅធ្វើការគ្រប់គ្រងលើជោគវាសនារបស់ខ្លួន ប្រកបដោយជោគជ័យ ។

សូមគោរពជូនពរ សម្តេចនាយករដ្ឋមន្ត្រី និងលោកជំទាវ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស បងប្អូនជនពិការទាំងអស់ ប្រកបដោយពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ !**